**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៤៩៧០ **អយក.ឋាក**

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២១

## ជម្រាបជូន

- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
- **លោកលោកស្រី ប្រធានការិយាល័យអប់រំ យុវជននិងកីឡារដ្ឋបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រី នាយក នាយិកាគ្រឹះស្ថានសិក្សាសាធារណៈ**

**កម្មវត្ថុៈ** ករណីការផ្តល់ឧបករណ៍តេស្តរហ័សអង់ទីហ្សែន និងសម្ភារការពារជំងឺកូវីដ-១៩ ជូនគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសម្រាប់ប្រើប្រាស់ឆ្នាំសិក្សា២០២០-២០២១។

**យោងៈ** -ការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

-សេចក្តីណែនាំលេខ ៦០ អយក.សណន ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក លោកស្រី** ជ្រាបថាៈ បន្ទាប់ពីស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា មានការស្រាកស្រាន្ត ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំលេខ៦០ អយក.សណន ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀននិងបង្រៀនតាមបណ្តុំសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅគ្រប់កម្រិត គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ក្នុងគោលបំណងបើកគ្រឹះស្ថានសិក្សាឡើងវិញទូទាំងប្រទេស ដើម្បីបន្តនិរន្តរភាពនៃការសិក្សាឱ្យបញ្ចប់ឆ្នាំសិក្សាប្រព្រឹត្តទៅប្រកបដោយគុណភាពនិងលទ្ធផលអាចទទួលយកបាន។ ទន្ទឹមនឹងនេះ សម្រាប់ការបើកដំណើរការគ្រឹះស្ថានសិក្សាគ្រប់កម្រិតថ្នាក់ឡើងវិញ សកម្មភាពដែលជាអាទិភាពបំផុត គឺការយកចិត្តទុកដាក់ខ្ពស់លើវិធានការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ដល់សិស្សានុសិស្ស គ្រូបង្រៀន អាណាព្យាបាល និងសហគមន៍ទាំងមូល។ ដូចនេះ ចាំបាច់ត្រូវអនុវត្តគោលការណ៍ប្រតិបត្តិការស្តង់ដា(SOP)របស់ក្រសួងសុខាភិបាលជានិច្ចនិរន្តរ៍។ ក្នុងន័យនេះ ក្រសួងក៏បានចូលរួមចំណែកផ្តល់នូវឧបករណ៍តេស្តរហ័សអង់ទីហ្សែន និងសម្ភារការពារជំងឺកូវីដ១៩មួយចំនួនជូនដល់គ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ប្រើប្រាស់ជាប្រយោជន៍ក្នុងការលើកកម្ពស់សុខុមាលភាពគ្រូបង្រៀននិងសិស្សានុសិស្សគ្រប់កម្រិតថ្នាក់សម្រាប់ឆ្នាំសិក្សា២០២០-២០២១ ដូចខាងក្រោមៈ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ក. គ្រឹះស្ថានសិក្សាសាធារណៈ៖

១. ឧបករណ៍តេស្តរហ័សអង់ទីហ្សែន

១.១. មត្តេយ្យសិក្សាផ្តល់ជូនចំនួន ៖ ៤០គ្រឿង/សាលា

១.២. បឋមសិក្សាផ្តល់ជូនចំនួន ៖ ៤០គ្រឿង/សាលា

១.៣. អនុវិទ្យាល័យផ្តល់ជូនចំនួន ៖ ៨០គ្រឿង/សាលា

១.៤. វិទ្យាល័យផ្តល់ជូនចំនួន ៖ ៨០គ្រឿង/សាលា

១.៥. វិទ្យាល័យបច្ចេកទេសផ្តល់ជូនចំនួន ៖ ៨០គ្រឿង/សាលា

២. ឧបករណ៍វាស់កំដៅនិងលាងដៃ

២.១. មត្តេយ្យសិក្សាផ្តល់ជូនចំនួន ៖ ១គ្រឿង/សាលា

២.២. បឋមសិក្សាផ្តល់ជូនចំនួន ៖ ១គ្រឿង/សាលា

២.៣. អនុវិទ្យាល័យផ្តល់ជូនចំនួន ៖ ២គ្រឿង/សាលា

២.៤. វិទ្យាល័យផ្តល់ជូនចំនួន ៖ ៣គ្រឿង/សាលា

២.៥. វិទ្យាល័យបច្ចេកទេសផ្តល់ជូនចំនួន ៖ ៣គ្រឿង/សាលា

៣. សាប៊ូដុំ

៣.១. មត្តេយ្យសិក្សាផ្តល់ជូនចំនួន ៖ ៦ដុំ/សាលា

៣.២. បឋមសិក្សាផ្តល់ជូនចំនួន ៖ ១២ដុំ/សាលា

៣.៣. អនុវិទ្យាល័យផ្តល់ជូនចំនួន ៖ ១២ដុំ/សាលា

៣.៤. វិទ្យាល័យផ្តល់ជូនចំនួន ៖ ១២ដុំ/សាលា

៣.៥. វិទ្យាល័យបច្ចេកទេសផ្តល់ជូនចំនួន ៖ ១២ដុំ/សាលា

៤. ម៉ាស់

៤.១. មត្តេយ្យសិក្សាផ្តល់ជូនចំនួន ៖ ៥ប្រអប់/សាលា

៤.២. បឋមសិក្សាផ្តល់ជូនចំនួន ៖ ១២ប្រអប់/សាលា

៤.៣. អនុវិទ្យាល័យផ្តល់ជូនចំនួន ៖ ២០ប្រអប់/សាលា

៤.៤. វិទ្យាល័យផ្តល់ជូនចំនួន ៖ ២០ប្រអប់/សាលា

៤.៥. វិទ្យាល័យបច្ចេកទេសផ្តល់ជូនចំនួន ៖ ២០ប្រអប់/សាលា

ខ. អង្គភាព៖

១. ឧបករណ៍តេស្តរហ័សអង់ទីហ្សែន

១.១.មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តផ្តល់ជូនចំនួន ៖ ៨០គ្រឿង/មន្ទីរ.អយក

១.២.ការិយាល័យ.អយកនៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌផ្តល់ជូនចំនួន ៖២០គ្រឿង/ក្រុងស្រុក/ខណ្ឌ

២. ឧបករណ៍វាស់កំដៅនិងលាងដៃ

២.១. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តផ្តល់ជូនចំនួន ៖ ២គ្រឿង/មន្ទីរ.អយក

២.២. ការិយាល័យ.អយកនៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌផ្តល់ជូនចំនួន៖១គ្រឿង/ក្រុងស្រុក/ខណ្ឌ

៣. សាប៊ូដុំ

៣.១. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តផ្តល់ជូនចំនួន ៖ ១២ដុំ/មន្ទីរ.អយក

៣.២. ការិយាល័យ.អយកនៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌផ្តល់ជូនចំនួន៖ ៤ដុំ/ក្រុងស្រុក/ខណ្ឌ

៤. ម៉ាស់

៤.១. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តផ្តល់ជូនចំនួន ៖ ១២ប្រអប់/មន្ទីរ.អយក

៤.២. ការិយាល័យ.អយកនៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌផ្តល់ជូនចំនួន ៖ ១០ប្រអប់/ក្រុងស្រុក/ខណ្ឌ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** ចូលរួមចាត់ចែងឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវខ្ពស់។

សូម **លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារនាយកដ្ឋានហិរញ្ញវត្ថុ